**ធនាគារអភិវឌ្ឍន៍អាស៊ី**

# របាយការណ៍សរុបរបស់

# ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស

# ស្តីពី

# គម្រោងសាងសង់ផ្លូវអន្តរជាតិពីរាជធានីភ្នំពេញទៅកាន់ទីក្រុងហូជីមិញ

# ក្នុងប្រទេសកម្ពុជា

**ប្រាក់កម្ចីរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ១៦៥៩-CAM (SF) (ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៨)**

**(ពាក្យបណ្តឹងដែលទទួលបាននៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧)**

ខែមិថុនា ឆ្នាំ២០១០

## អក្សរកាត់

| | |
|---|---|
| ADB: | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AP: | ប្រជាជនដែលទទួលរងផលប៉ះពាល់ |
| CARM: | បេសកកម្មនិវាសនដ្ឋាននៅកម្ពុជា |
| CDCam: | អង្គការអភិរក្ស និងអភិវឌ្ឍន៍កម្ពុជា |
| IRC: | គណៈកម្មាធិការតាំងទីលំនៅអន្តរក្រសួង |
| MEF: | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| NGO: | អង្គការមិនមែនរដ្ឋាភិបាល |
| OSPF | ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស |
| RAR: | របាយការណ៍បូកសរុប និងវាយតម្លៃ |
| TA: | ជំនួយបច្ចេកទេស |

ឯកសារនេះត្រូវបានបកប្រែចេញពីអត្ថបទជាភាសាអង់គ្លេស មកជាភាសាខ្មែរ ។ អត្ថបទជាភាសាអង់គ្លេសគឺជាអត្ថបទផ្លូវការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ហើយមានតែអត្ថបទដើមជាភាសាអង់គ្លេសប៉ុណ្ណោះដែលមានលក្ខណៈយថាភូត អាចយោង ឬធ្វើជាសំអាងផ្លូវការបាន ។ រាល់ការធ្វើសេចក្តីយោងលើអត្ថបទនេះ ចាំបាច់ត្រូវយោងទៅលើអត្ថបទដើមជាភាសាអង់គ្លេស ។ ធនាគារអភិវឌ្ឍន៍អាស៊ី មិនធានាខុសត្រូវចំពោះភាពសុក្រឹត្យត្រឹមត្រូវនៃការបកប្រែជាភាសាខ្មែរ ហើយក៏មិនទទួលខុសត្រូវចំពោះចំនុចដែលអាចមានអត្ថន័យខុសពីខ្លឹមសារនៃអត្ថបទដើមឡើយ ។

នៅពេលរៀបចំកម្មវិធី ឬរៀបចំយុទ្ធសាស្ត្រ ឬផ្តល់ជំនួយហិរញ្ញវត្ថុសម្រាប់គម្រោងណាមួយនោះ ឬការនិយាយយោងទៅដល់ទឹកដី ឬទីតាំងភូមិសាស្ត្រជាក់លាក់ណាមួយនោះ ធនាគារអភិវឌ្ឍន៍អាស៊ីមិនមាន ចេតនាវាយតម្លៃស្ថានភាពផ្លូវច្បាប់ ឬស្ថានភាពអ្វីផ្សេងទៀតរបស់ទឹកដី ឬទីតាំងភូមិសាស្ត្រនោះទេ ។

# មាតិកា

**ទំព័រ**

**សេចក្តីសង្ខេប ..................................................................................................... ៤**

**ផែនទី.................................................................................................................. ៧**

**១. សាវតារ ............................................................................................................. ៨**

ក. គម្រោង .................................................................................................... ៨

ខ. បណ្តឹងទាមទារ ........................................................................................... ៩

គ. ការកំណត់ពីសិទ្ធិទទួលបាន.......................................................................... ១០

**២. ការពិនិត្យឡើងវិញ និងការវាយតម្លៃ ................................................................... ១០**

ក. វិធីសាស្ត្រ.................................................................................................. ១០

ខ. ការកំណត់ភាគីពាក់ព័ន្ធ................................................................................. ១០

គ. លទ្ធផលរកឃើញ និងអនុសាសន៍ .................................................................. ១១

ឃ. ការចាត់វិធានការដែលបានស្នើឡើង.............................................................. ១២

**៣. ទិសដៅសកម្មភាព............................................................................................. ១៣**

# សេចក្តីសង្ខេប

មហាអនុតំបន់ទន្លេមេគង្គ ៖ គម្រោងសាងសង់ផ្លូវអន្តរជាតិពីរាជធានីភ្នំពេញទៅកាន់ទីក្រុងហូជីមិញ ប្រើប្រាស់ប្រាក់កម្ចីចំនួនពីរ ប្រាក់កម្ចីមួយសម្រាប់ប្រទេសកម្ពុជា និងប្រាក់កម្ចីមួយទៀតសម្រាប់ប្រទេសវៀតណាម។ ចំណែកការងារក្នុងប្រទេសកម្ពុជា រួមមានការជួសជុលផ្លូវឡើងវិញប្រវែង ១០៥ គីឡូម៉ែត្រ ចាប់ពីកំពង់ចម្លងអ្នកលឿងត្រើយខាងកើតទន្លេមេគង្គ រហូតដល់បាវិតដែលស្ថិតនៅជាប់ព្រំប្រទល់ប្រទេសវៀតណាម ព្រមទាំងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធថ្មីៗនៅចំណុចព្រំដែនផងដែរ។ ក្រសួងសាធារណការ និងដឹកជញ្ជូន គឺជាស្ថាប័នប្រតិបត្តិ ហើយគណៈកម្មាធិការតាំងទីលំនៅអន្តរក្រសួង (IRC) ក្រោមការដឹកនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទទួលខុសត្រូវលើការរៀបចំផែនការ និងការអនុវត្តការតាំងទីលំនៅ ពាក់ព័ន្ធនឹងគម្រោងនេះ។

ក្នុងខែកក្កដា ឆ្នាំ២០០៧ ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស (OSPF) បានទទួលពាក្យបណ្តឹងទាមទារចំនួនពីរច្បាប់ដែលទាក់ទងនឹងគម្រោងពីសហគមន៍ក្រាំងក្អុក និងស្ទឹងស្លូត ខេត្តព្រៃវែង ដោយនៅក្នុងពាក្យបណ្តឹងទាមទារនោះមានរាយឈ្មោះប្រជាជនដែលទទួលរងផលប៉ះពាល់ (APs) សរុបចំនួន ៦៣ នាក់ ដែលមានទីលំនៅស្ថិតនៅក្នុងគម្រោងសាងសង់នេះ។ ពាក្យបណ្តឹងទាមទារនេះបានសរសេរថា ទោះបីជាមានការធ្វើសវនកម្មលើការតាំងទីលំនៅសាជាថ្មី និងមានការទូទាត់សំណងក៏ដោយ ក៏បញ្ហារបស់ប្រជាជនដែលទទួលរងផលប៉ះពាល់ នៅតែមិនទាន់បានដោះស្រាយ ហើយអ្នកទាំងនោះគឺជាប្រជាជនក្រីក្រ បាត់បង់មុខរបរចិញ្ចឹមជីវិត និងជំពាក់បំណុលយ៉ាងច្រើនលើសលប់។ ពាក្យបណ្តឹងបានស្នើសុំជំនួយបន្ថែមទៀត រួមទាំង ការផ្តល់មូលនិធិ កម្មសិទ្ធិលើដីតាំងទីលំនៅសាជាថ្មី និងគម្រោងស្តីពីការបង្កើតការងារ។

ផ្អែកតាមមូលដ្ឋាននៃបេសកកម្មលើតំបន់គម្រោង និងការពិភាក្សាជាមួយភាគីពាក់ព័ន្ធ ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស បានយល់ឃើញថា ពាក្យបណ្តឹងទាមទារ អាចទទួលយកទៅរួមបញ្ចូលក្នុងដំណាក់កាលនៃការប្រឹក្សាអំពីយន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស បានធ្វើការបូកសរុប និងវាយតម្លៃលើពាក្យបណ្តឹងទាមទារ ដែលតម្រូវឱ្យយកឯកសារ និងព័ត៌មានដែលប្រមូលបានក្នុងអំឡុងពេលបំពេញបេសកកម្ម មកធ្វើការពិនិត្យវាយតម្លៃ និងពិចារណាសាជាថ្មីឡើងវិញ។ ការិយាល័យអ្នកសម្របសម្រួល បានធ្វើចរាចររបាយការណ៍បូកសរុប និងវាយតម្លៃ (RAR) ក្នុងធនាគារអភិវឌ្ឍន៍អាស៊ី និងបានបញ្ជូនរបាយការណ៍នេះទៅកាន់ដើមបណ្តឹង (របាយការណ៍ដែលបានបកប្រែជាភាសាខ្មែរ) នៅខែតុលា ឆ្នាំ២០០៧។

របាយការណ៍បូកសរុប និងវាយតម្លៃការងារ បានកំណត់ថា ភាគីពាក់ព័ន្ធ រួមមាន ដើមបណ្តឹងចំនួន ៦៣ នាក់ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន គណៈកម្មាធិការតាំងទីលំនៅអន្តរក្រសួង និងបេសកកម្មនិវាសនដ្ឋានក្នុងប្រទេសកម្ពុជារបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ការិយាល័យអ្នកសម្របសម្រួល បានដាក់បញ្ចូលបញ្ហាគម្រោងស្ថិតក្រោមប្រធានបទសំខាន់ចំនួនពីរ ដែលរួមមាន បញ្ហាកម្មសិទ្ធិដីធ្លី និងបញ្ហាក្រីក្រ។ ដើមបណ្តឹង បានបង្ហាញពីក្តីព្រួយបារម្ភយ៉ាងខ្លាំងថា ពួកគាត់អាចនឹងមិនទទួលបានកម្មសិទ្ធិលើដីធ្លីមកវិញ នៅពេលដែលពួកគាត់ទៅតាំងទីលំនៅក្នុងកន្លែងផ្សេង បន្ទាប់ពីដីរបស់ពួកគាត់ត្រូវបានប្រើក្នុងការសាងសង់ផ្លូវ។ នៅពេលដែលពួកគាត់ មានការព្រួយបារម្ភពីការមិនទទួលបានកម្មសិទ្ធិលើដីធ្លី ពួកគាត់អាចជាជនរងគ្រោះក្នុងការបាត់បង់ដីរបស់ខ្លួន ។ ដើមបណ្តឹងជាច្រើន បានបាត់បង់ប្រភពប្រកបរបរចិញ្ចឹមជីវិតរបស់ខ្លួនក្នុងពេលកន្លងមក នៅពេលដែលពួកគាត់ ត្រូវបានបង្ខំឱ្យប្តូរទីលំនៅ និងពុំមានការបង្កើតកម្មវិធីណាមួយ ដើម្បីជួយពួកគាត់ក្នុងការបង្កើតមុខរបរ បន្ទាប់ពីមានការប្តូរ

ទីលំនៅនោះទេ។ ដើមបណ្តឹងជាច្រើន បានខ្ចីលុយពីអ្នកចងការដោយមានអត្រាការប្រាក់ខ្ពស់ហួសហេតុ និងបានជំពាក់បំណុលយ៉ាងច្រើន ដោយសារការបាត់បង់ប្រភពចំណូលរបស់ខ្លួននាពេលកន្លងមក និងមិនអាចខ្ចីប្រាក់ពីធនាគារពាណិជ្ជកម្ម ពីព្រោះពួកគាត់មិនមានប័ណ្ណកម្មសិទ្ធិដីធ្លី។ ពួកគាត់ជឿជាក់ថា កម្មវិធីបង្កើតមុខរបរ និងការលោះបំណុលក្នុងទម្រង់ផ្សេងៗ មានសារៈសំខាន់ក្នុងការធ្វើឱ្យស្ថានភាពរស់នៅរបស់ពួកគាត់ មានភាពប្រសើរឡើងវិញ ដូចនឹងស្ថានភាពនៅមុនពេលការចាប់ផ្តើមគម្រោង។

របាយការណ៍បូកសរុប និងវាយតម្លៃ បានទទួលស្គាល់ថា ភាគីពាក់ព័ន្ធសំខាន់ៗ មិនបានធានាពីការប្តេជ្ញាចិត្តក្នុងដំណើរការពិគ្រោះយោបល់នោះទេ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គណៈកម្មាធិការតាំងទីលំនៅអន្តរក្រសួង និងបេសកកម្មនិវាសនដ្ឋានក្នុងប្រទេសកម្ពុជា បានជឿជាក់ថា ពួកគេអាចដោះស្រាយបញ្ហាលេចធ្លោទាំងនេះ ដោយមិនត្រូវការជំនួយពីដំណើរការពិគ្រោះយោបល់របស់ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេសនោះទេ។ ផ្ទុយទៅវិញ ដើមបណ្តឹងមិនមានជំនឿទុកចិត្តថា វិធីសាស្ត្រនេះ នឹងទទួលបានជោគជ័យនោះទេ ហើយរបាយការណ៍បូកសរុប និងវាយតម្លៃការងារ បានសន្និដ្ឋានថា ការដោះស្រាយបញ្ហារបស់ដើមបណ្តឹង តាមរយៈការពិគ្រោះយោបល់ គឺមានភាពលំបាកក្នុងការប៉ាន់ស្មាន ហើយជារួម គឺអាស្រ័យលើទង្វើនៃដំណើរការនេះ។ ស្ថិតក្នុងកាលៈទេសៈនេះ របាយការណ៍បូកសរុប និងវាយតម្លៃការងារ បានលើកឡើងថា វិធីដ៏ល្អក្នុងការអនុវត្តបន្តទៀត គឺត្រូវអនុវត្តតាមជំហានដែលមានរៀបរាប់ក្នុងដំណើរការពិគ្រោះយោបល់របស់ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស។ ដើមបណ្តឹង នឹងត្រូវយល់ពីរបាយការណ៍បូកសរុប និងការវាយតម្លៃការងារនេះ និងបន្ទាប់មក ធ្វើការសម្រេចថា តើគួរអនុវត្តដំណើការពិគ្រោះយោបល់ដែរឬទេ ឬត្រូវបញ្ឈប់ដំណើរការនេះ ប្រសិនបើពួកគាត់រកឃើញថា ដំណើរការពិគ្រោះយោបល់នេះមិនមានការតាំងចិត្តក្នុងការដោះស្រាយបញ្ហា។

ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស បានផ្តល់អ្នកប្រឹក្សាឯករាជ្យ ដើម្បីជួយដល់ដើមបណ្តឹងឱ្យយល់ពីរបាយការណ៍បូកសរុប និងការវាយតម្លៃ ព្រមទាំងការសម្រេចចិត្តដែលពួកគាត់ត្រូវធ្វើក្នុងការបន្តដំណើរការពិគ្រោះយោបល់។ ក្នុងអំឡុងពេលប្រជុំជាមួយអ្នកប្រឹក្សា ដើមបណ្តឹងចំនួន ៥២ នាក់ក្នុងចំណោម ៦៣ នាក់ បានបញ្ជាក់ថា ពួកគាត់ចង់បន្តដំណើរការពិគ្រោះយោបល់។ ស្របពេលជាមួយគ្នានេះដែរ ក្នុងខែវិច្ឆិកា ឆ្នាំ២០០៧ បេសកកម្មនិវាសនដ្ឋានក្នុងប្រទេសកម្ពុជា បានធ្វើបទសម្ភាសជាមួយគ្រួសារចំនួន ៦៣ គ្រួសារ ព្រមទាំងបានរៀបចំការប្រជុំក្នុងខែវិច្ឆិកា និងខែធ្នូ ដើម្បីពិភាក្សាលើលទ្ធផលរកឃើញក្នុងការធ្វើបទសម្ភាស និងពិចារណារកជំហានបន្ទាប់ទៀត។ បេសកកម្មនិវាសនដ្ឋានក្នុងប្រទេសកម្ពុជា គណៈកម្មាធិការតាំងទីលំនៅអន្តរក្រសួង និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន បានព្រមព្រៀងបន្តដំណើរការក្នុងការទាមទារឱ្យមានការពិចារណាលើចម្លើយរបស់ដើមបណ្តឹងក្នុងអំឡុងពេលធ្វើបទសម្ភាស និងការផ្តល់មតិយោបល់ពីអង្គការមិនមែនរដ្ឋាភិបាលរួមជាមួយនឹងទស្សនៈ ក្នុងការដោះស្រាយបញ្ហាដែលបានលើកឡើង។

ដោយធ្វើការពិចារណាលើការសម្រេចចិត្តរបស់ដើមបណ្តឹង ដើម្បីបន្តដំណើរការពិគ្រោះយោបល់ ការិយាល័យអ្នកសម្រួលសម្រួលគម្រោងពិសេស បានឈានទៅកាន់ជំហានបន្ទាប់ក្នុងដំណើរការពិគ្រោះយោបល់ ហើយក្នុងខែមករា ឆ្នាំ២០០៨ ការិយាល័យបានស្នើឱ្យដើមបណ្តឹង និងបេសកកម្មនិវាសនដ្ឋានក្នុងប្រទេសកម្ពុជា ផ្តល់មតិយោបល់លើរបាយការណ៍បូកសរុប និងការវាយតម្លៃការងារ។ បេសកកម្មនិវាសនដ្ឋានក្នុងប្រទេសកម្ពុជា បានផ្តល់មតិយោបល់ ប៉ុន្តែដើមបណ្តឹងមិនបានផ្តល់មតិយោបល់នោះទេ ហើយបែរជាស្នើឱ្យការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស ពន្យារដំណើការពិគ្រោះយោបល់ខណៈពេលកិច្ចខិតខំប្រឹងប្រែងរបស់បេសកកម្មនិវាសនដ្ឋានក្នុងប្រទេសកម្ពុជា និងគណៈកម្មាធិការតាំងទីលំនៅអន្តរក្រសួង ក្នុងការដោះស្រាយបញ្ហារបស់ពួកទើបតែចាប់ផ្តើម។ ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស យល់ព្រមពន្យារដំណើរការពិគ្រោះ

យោបល់របស់ខ្លួន និងរង់ចាំលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរួមរបស់បេសកកម្មនិវាសនដ្ឋានក្នុងប្រទេសកម្ពុជា និងគណៈកម្មាធិការតាំងទីលំនៅអន្តរក្រសួងក្នុងការដោះស្រាយបញ្ហា ដែលដើមបណ្តឹងបានលើកឡើង។

កិច្ចខិតខំប្រឹងប្រែងរួមរបស់បេសកកម្មនិវាសនដ្ឋានក្នុងប្រទេសកម្ពុជា និងគណៈកម្មាធិការតាំងទីលំនៅអន្តរក្រសួងក្នុងការស្វែងរកដំណោះស្រាយដល់បញ្ហារបស់ដើមបណ្តឹង ត្រូវពន្យារពេលដោយសារមូលហេតុជាច្រើន ប៉ុន្តែនៅខែតុលា ឆ្នាំ២០០៩ ធនាគារអភិវឌ្ឍន៍អាស៊ី បានយល់ព្រមផ្តល់ជំនួយបច្ចេកទេសដែលរួមបញ្ចូលទាំងកម្មវិធីបង្កើតឱ្យមានចំណូលឡើងវិញ ក្នុងគោលបំណងជួយដល់ដើមបណ្តឹងក្នុងការដោះស្រាយបំណុលដ៏ច្រើនលើសលុបរបស់ពួកគាត់ និងបង្កើតឱ្យមានសកម្មភាពរកប្រាក់ចំណូលឡើងវិញ។ ការបង្កើតកម្មវិធីនេះ ផ្តល់សេចក្តីសង្ឃឹមក្នុងការដោះស្រាយបញ្ហា ដែលដើមបណ្តឹងបានស្នើឱ្យការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស ធ្វើការដោះស្រាយ។ ការិយាល័យអ្នកសម្របសម្រួល បានផ្តល់ព័ត៌មានដល់ដើមបណ្តឹងនៅខែវិច្ឆិកា ឆ្នាំ២០០៩ ពីការបិទការប្តឹងតវ៉ា ហើយនៅខែឧសភា ឆ្នាំ២០១០ អ្នកសម្របសម្រួលគម្រោងពិសេស បានចុះទៅជួបដើមបណ្តឹង ដើម្បីបិទការប្តឹងតវ៉ា និងប្រាប់ពីការផ្ទេរការងារក្នុងការដោះស្រាយបញ្ហារបស់ពួកគេទៅឱ្យក្រុមជំនួយបច្ចេកទេស។

## ផែនទី



104°00'E
107°00'E
CAMBODIA AND VIET NAM
GREATER MEKONG SUBREGION:
HO CHI MINH CITY TO PHNOM PENH HIGHWAY PROJECT
Tonle Sap
Kompong Thom
12°30'N
Pursat
Kratie
Mekong River
Kompong Chhang
Snoul
Kompong Cham
B. Dang Krien
Binh Long
CAMBODIA
PHNOM PENH
Prey Veng
Bao Loc
Tay Ninh
Chon Thanh
Kompong Speu
Kompong Trabec
Dong Xoai
Noek Loeung
Moc Bai
Sre Umbell
Svay Rieng
Go Dau
Thu Dau Mot
Takeo
Bavet
Bien Hoa
Veal Renh
Chau Phu
An Suong
Thu Duc
Sihanoukville
Kampot
Cho Lon
HO CHI MINH CITY (SAIGON)
Kep
VIET NAM
Tan An
Ha Tien
Long Xuyen
My Tho
Vung Tau
Duong Dong
Hon Chong
Vinh Long
Rach Gia
Can Tho
Ba Dong
Soc Trang
Khanh Hung
Gulf of Thailand
Mouth of Mekong
Ca Mau
Bac Lieu
Quan Long
9°00'N
Nam Can
N
0 10 20 30 40 50 100
Kilometers
National Capital
Provincial Capital
City/Town
Airport
Project Road
Main Road
Secondary Road
Railway
River
International Boundary
Boundaries are not necessarily authoritative.
10-1081 HR

# ១. សារសារ

## ក. គម្រោង

១. មហាអនុតំបន់ទន្លេមេគង្គ ៖ គម្រោងសាងសង់ផ្លូវអន្តរជាតិពីរាជធានីភ្នំពេញទៅកាន់ទីក្រុងហូជីមិញ បានអនុម័តដោយគណៈនាយករបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៨ និងបែងចែកកម្ចីជា ២ ដែលក្នុងនោះកម្ចីមួយសម្រាប់ប្រទេសកម្ពុជា (កម្ចី 1659-CAM[SF]) និងកម្ចីមួយទៀតសម្រាប់ប្រទេសវៀតណាម (កម្ចី1660-VIE[SF])។ ចំណែកការងារសម្រាប់ប្រទេសកម្ពុជា រួមមានការសាងសង់ឡើងវិញនៃផ្លូវជាតិលេខ ១ ប្រវែង ១០៥ គីឡូម៉ែត្រ គិតចាប់ពីកំពង់ចម្លងអ្នកលឿងនៅត្រើយខាងកើតនៃទន្លេមេគង្គ ទៅបាវិតដែលស្ថិតនៅជាប់ព្រំប្រទល់ប្រទេសវៀតណាម ព្រមទាំងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធថ្មីៗនៅតាមព្រំដែន (ផែនទី ទំព័រទី vi)។ កម្ចីនេះចាប់មានប្រសិទ្ធភាពពីថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៩៩ និងត្រូវបិទនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៦។ ក្រសួងសាធារណការ និងដឹកជញ្ជូន គឺជាស្ថាប័នប្រតិបត្តិ។ គណៈកម្មាធិការតាំងទីលំនៅអន្តរក្រសួង(IRC) ក្រោមការដឹកនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) ទទួលខុសត្រូវលើការធ្វើផែនការ និងការអនុវត្តការតាំងទីលំនៅពាក់ព័ន្ធនឹងគម្រោងនេះ[១]។

២. នៅឆ្នាំ២០០២ អង្គការមិនមែនរដ្ឋាភិបាល (NGOs) ចំនួន ២ បានបញ្ជូនរបាយការណ៍មក ADB ដោយលើកឡើងអំពីការទទួលបានសំណងមិនសមស្របរបស់គ្រួសារមួយចំនួនដែលបានផ្លាស់ប្តូរទីលំនៅ និងលើកឡើងពីការចោទប្រកាន់ទាក់ទងនឹងការអនុវត្តតាមរបាយការណ៍ និងអនុសាសន៍របស់ប្រធាន និងកិច្ចព្រមព្រៀងផ្តល់ប្រាក់កម្ចី។ ADB បានស្នើឱ្យធ្វើសវនកម្មដោយឯករាជ្យ លើការតាំងទីលំនៅ ដើម្បីស្វែងយល់ និងដាក់ចេញវិធានការដោះស្រាយបញ្ហាដែលកើតមាន។ សវនកម្មនេះ ធ្វើឡើងដោយក្រុមអ្នកផ្តល់ប្រឹក្សា (ដែលទទួលបានហិរញ្ញប្បទានពីជំនួយបច្ចេកទេស (TA)[២] ADB (NGOs)) ជួបផ្សំនឹង IRC និងវេទិកា NGO នៅកម្ពុជា ចាប់ពីខែវិច្ឆិកា ឆ្នាំ២០០៤ ដល់ខែមីនា ឆ្នាំ២០០៥ ចំណែករបាយការណ៍នៃការធ្វើសវនកម្មនេះ បានលើកឡើងថា ផែនការសកម្មភាព ត្រូវយកមកអនុវត្តដោយដាក់បញ្ចូលនូវការផ្តល់ប្រាក់សំណង និងប្រាក់ឧបត្ថម្ភនានាដល់ប្រជាជនដែលទទួលរងផលប៉ះពាល់(APs)[៣]។ ADB និងរដ្ឋាភិបាលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ដើម្បីធានាថា ប្រជាជនដែលទទួលរងផលប៉ះពាល់បានទទួលប្រាក់សំណងបន្ថែម

---

[១] IRC ត្រូវបានបង្កើតឡើងនៅខែកុម្ភៈ ឆ្នាំ១៩៩៩ ជាផ្លូវការដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ សមាជិកផ្សេងៗរបស់ IRC គឺជាតំណាងមកពីទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គណៈអភិបាលក្រុងភ្នំពេញ ព្រមទាំងអភិបាល និងអភិបាលរងខេត្តព្រៃវែង និងស្វាយរៀង។

[២] ADB. 2002. *TA for Capacity Building for Resettlement Risk Management*. Manila (TA 6091-REG). http://wpddoc1.asiandevbank.org/482573EF000C8A15/AllByUnid/AEDFD18370D73B084825757900245A59/$FILE/R36-03.pdf

[៣] ADB. 2006. *Resettlement Audit: Phnom Penh to Ho Chi Minh City Highway Improvement Project (Loan 1659-CAM), Final*. Manila. http://www.adb.org/Documents/Resettlement_Plans/CAM/30513/default.asp

សមស្របផ្អែកលើលទ្ធផលសវនកម្ម ហើយការចំណាយលើសំណងនេះត្រូវបានធ្វើឡើងក្នុងឆ្នាំ២០០៦[៤] ។ ទោះជាយ៉ាងណា វេទិកាអង្គការមិនមែនរដ្ឋាភិបាល NGO នៅកម្ពុជា នៅតែបន្តលើកឡើងនូវបញ្ហាពាក់ព័ន្ធនឹងគ្រួសារដែលអះអាងថាពួកគាត់ពុំទទួលបានប្រាក់សំណង ។ របាយការណ៍ស្តីពីការបញ្ចប់គម្រោង ត្រូវបានចេញផ្សាយនៅខែធ្នូ ឆ្នាំ២០០៧[៥] ។

## ខ. បណ្តឹងទាមទារ

៣. នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស (OSPF) បានទទួលលិខិតបណ្តឹងចំនួន ២ ជាភាសាខ្មែរ[៦] ពាក់ព័ន្ធនឹងគម្រោងនេះ ដូចមានក្នុងឯកសារភ្ជាប់តាមរយៈអ៊ីមែលផ្ញើមកពីប្រធានស្តីទីនៃ NGO ក្នុងប្រទេស ហៅថា អង្គការអភិរក្ស និងអភិវឌ្ឍន៍កម្ពុជា (CDCam)។ លិខិតមួយផ្ញើមកពីអ្នកដឹកនាំសហគមន៍នៅក្រាំងក្អក ខេត្តព្រៃវែង ដោយមានរាយនាមប្រជាជនដែលរងគ្រោះចំនួន ៤១នាក់ លិខិតមួយទៀតផ្ញើមកពីអ្នកដឹកនាំសហគមន៍ស្ទឹងស្លួត ខេត្តព្រៃវែងដដែល ដោយមានរាយនាមប្រជាជនរងគ្រោះចំនួន ២២នាក់ ។ លិខិតទាំងនេះបានលើកឡើងថាមានការធ្វើសវនកម្ម ប៉ុន្តែបញ្ហារបស់ប្រជាជនដែលទទួលរងផលប៉ះពាល់ នៅតែពុំទាន់ត្រូវបានដោះស្រាយនៅឡើយទេ លើសពីនោះទៀត អ្នកទាំងនោះ សុទ្ធតែជាជនក្រីក្រ ព្រមទាំងបាត់បង់របរចិញ្ចឹមជីវិត និងជំពាក់បំណុលយ៉ាងច្រើន ។ លិខិតទាំងពីរនេះ បានលើកឡើងអំពី "ការផ្តល់មូលនិធិបន្ថែម" កម្មសិទ្ធិដីធ្លីរបស់ខ្លួន "គម្រោងស្តីពីការផ្តល់ការងារ" ដោយស្នើឱ្យ OSPF ធ្វើការអង្កេតសម្រាប់ខ្លួន និងគ្រួសាររងគ្រោះផ្សេងៗទៀត រួមទាំងគ្រួសាររងគ្រោះដែលពុំទាន់ទទួលបានប្រាក់សំណងពេញលេញ និងស្នើឱ្យ OSPF "រៀបចំ និងបង្កើតដំណើរការគម្រោង ដោយមិនប៉ះពាល់ដល់ប្រជាជន"។ អ្នកផ្ញើលិខិតទាំងនោះ ក៏បានឱ្យដឹងផងដែរថា ខ្លួននឹងបញ្ជូនឯកសារបន្ថែមទៀត ។ លិខិតបណ្តឹងទាមទារទាំងពីរនោះ បានផ្តល់សិទ្ធិឱ្យប្រធានស្តីទីរបស់ CDCam ធ្វើជាអ្នកតំណាងសម្រាប់ការទំនាក់ទំនងរបស់គេ ។

៤. OSPF បានបញ្ជាក់ថាខ្លួនបានទទួលលិខិតទាំងនេះ នៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៧ ដោយបានកត់ត្រាក្នុងបញ្ជីបណ្តឹងទុកជា ពាក្យបណ្តឹងនៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧ និងទទួលបានឯកសារបន្ថែមនៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៧។ ឯកសារបន្ថែម រួមមានបញ្ជីឈ្មោះអ្នកភូមិចំនួន ១៧០នាក់ទៀត "ដែលរងគ្រោះដោយសារគម្រោងនេះ និងពុំទាន់បានទទួលប្រាក់សំណងសមស្រប និងយុត្តិធម៌នៅឡើយទេ ថែមទាំងកំពុងជួបការលំបាកទៀតផង" និងដើមបណ្តឹងក៏បានស្នើសុំការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេសធ្វើការស៊ើបអង្កេតលើករណីទាំងនេះ ។ ដើមបណ្តឹង បាននិយាយថា ពួកគេមិនបានស្នើសុំឱ្យមានភាពសម្ងាត់ពីពាក្យបណ្តឹងទាមទាររបស់ពួកគេទេ ហើយពួកគេបានផ្តល់សិទ្ធិឱ្យ OSPF ដើម្បីធ្វើការផ្សព្វផ្សាយរាល់ព័ត៌មានក្នុងបណ្តឹងនេះ ។

---

[៤] សូមមើលរបាយការណ៍ដំណាក់កាលទី២ ស្តីពី សវនកម្មលើការតាំងទីលំនៅឡើងវិញ (ibid)

[៥] ADB. 2007. *Completion Report: Kingdom of Cambodia and Socialist Republic of Viet Nam: Greater Mekong Subregion: Phnom Penh to Ho Chi Minh City Highway Project*. Manila. http://www.adb.org/Documents/PCRs/VIE/30316-VIE-PCR.pdf?bcsi_scan_7823DFCE46415F3E=2lRyoCW3PfEN5Jf0yDiUGgYAAAAHSvkE&bcsi_scan_filename=30316-VIE-PCR.pdf

[៦] លិខិតទាំងនេះមានជាភាសាខ្មែរ និងអង់គ្លេស ក្នុងបញ្ជីបណ្តឹងនៅលើវិបសាយថ៍របស់ OSPF www.adb.org/spf ។ លិខិតជាភាសាខ្មែរមាននៅ http://adb.org/Documents/Translations/Khmer/Krang-Khok-KH.pdf និង http://adb.org/Documents/Translations/Khmer/Steung-Slot-KH.pd ចំណែកការបកប្រែជាភាសាអង់គ្លេសមានក្នុង http://adb.org/SPF/documents/Krang-Khok.pdf និង http://adb .org/SPF/documents/Steung-Sloth.pdf ។

### គ. ការកំណត់ពីសិទ្ធិទទួលបាន

៥. អង្គការបេសកកម្មពិនិត្យលើសិទ្ធិទទួលបានរបស់ OSPF បានមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា ចាប់ពីថ្ងៃទី២៨ ខែសីហា ដល់ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០៧ និងបានជួបជាមួយបុគ្គលិកបេសកកម្មនិវាសនដ្ឋានប្រចាំកម្ពុជា (CARM) បុគ្គលិករបស់ CDCam បុគ្គលិករបស់ IRC អគ្គលេខាធិការរងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអ្នកដឹកនាំសហគមន៍ចំនួន ២ ទៀតដែលបានដាក់ពាក្យបណ្តឹង។ បេសកកម្មនេះ បានធ្វើដំណើរទៅកាន់ភូមិក្រាំងក្អក និងពិភាក្សាជាមួយអ្នកដឹកនាំសហគមន៍ទាំង២ ហើយក៏បានចុះទៅពិនិត្យដល់ទីកន្លែងតាំងទីលំនៅសាជាថ្មីនៅស្ទឹងស្លួតផងដែរ។ បញ្ហារបស់ដើមបណ្តឹងត្រូវបានលើកឡើងជាច្រើនឆ្នាំមកហើយ ប៉ុន្តែនៅតែពុំទាន់មានការដោះស្រាយនៅឡើយរហូតដល់ពេលបច្ចុប្បន្ននេះ។ ដើមបណ្តឹងបានសម្តែងការមិនពេញចិត្តយ៉ាងខ្លាំងចំពោះស្ថានភាពដែលមានភាពលំបាកជាងពីមុនពេលចាប់ផ្តើមគម្រោង ហើយខ្លួនសមនឹងទទួលបានជំនួយបន្ថែមទៀតលើសពីប្រាក់សំណងដែលផ្តល់បន្ទាប់ពីធ្វើសវនកម្មលើការតាំងទីលំនៅឡើងវិញ។ លទ្ធផលរកឃើញរបស់បេសកកម្ម OSPF បានបញ្ជាក់ថា ពាក្យបណ្តឹងនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ តទៅ។

## ២. ការពិនិត្យឡើងវិញ និងការវាយតម្លៃ

### ក. វិធីសាស្ត្រ

៦. OSPF បានរៀបចំផែនការ ដើម្បីចុះបេសកកម្មពិនិត្យឡើងវិញ និងវាយតម្លៃដល់កន្លែង ដើម្បីជួបជាមួយភាគីពាក់ព័ន្ធទាំងអស់ ព្រមទាំងធ្វើការពិភាក្សាអំពីបណ្តឹង និងស្វែងរកវិធីសាស្ត្រសមស្របដើម្បីដោះស្រាយបណ្តឹងនេះ ប៉ុន្តែរដ្ឋាភិបាលបានស្នើឱ្យមានការចុះបេសកកម្មនៅពេលក្រោយវិញ រហូតដល់រដ្ឋាភិបាលបានចងក្រងបញ្ហាតាំងទីលំនៅនេះឱ្យបានគ្រប់ជ្រុងជ្រោយសិន។ អាស្រ័យហេតុនេះ ការពិនិត្យឡើងវិញ និងការវាយតម្លៃធ្វើឡើង ដោយផ្អែកលើ (i) ឯកសារដែលផ្តល់ដោយដើមបណ្តឹង (ii) ឯកសាររបស់ ADB និង (iii) លទ្ធផលរកឃើញបានពីបេសកកម្មនៃសិទ្ធិទទួលបានរបស់ OSPF។

### ខ. ការកំណត់ភាគីពាក់ព័ន្ធ

៧. របាយការណ៍ស្តីពីការពិនិត្យឡើងវិញ និងវាយតម្លៃ (RAR) បានកំណត់ភាគីពាក់ព័ន្ធនានា រួមមាន ដើមបណ្តឹងចំនួន ៦៣ នាក់ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នរដ្ឋាភិបាលមួយចំនួន រួមទាំង IRC និង CARM របស់ ADB ផង។

៨. RAR បានរកឃើញដើមបណ្តឹងទាំង៦៣នាក់ ដូចមានឈ្មោះក្នុងលិខិតបណ្តឹងទាំង ២ ដែល OSPF ទទួលបាននៅថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០០៧។ OSPF មិនបានចាត់ទុកប្រជាជនចំនួន ១៧៧នាក់ផ្សេងទៀតជាដើមបណ្តឹងទេ ពីព្រោះប្រជាជនទាំងនោះមិនបានចុះហត្ថលេខា ឬធ្វើលិខិតប្រគល់សិទ្ធិជូនបុគ្គលណាម្នាក់ជាតំណាងរបស់ខ្លួនឡើយ ហើយ ករណីទាំងនេះត្រូវបាន IRC និង CARM លើកមកពិចារណាយ៉ាងម៉ត់ចត់។

៩. អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន គឺជាភាគីពាក់ព័ន្ធ។ ដើមបណ្តឹងបានប្រគល់សិទ្ធិដំបូងដល់ប្រធានស្តីទីរបស់ NGO ប្រចាំនៅកម្ពុជា ហៅថា CDCam ឱ្យធ្វើជាអ្នកទំនាក់ទំនង ហើយក្រោយមក (នៅថ្ងៃទី០១ ខែតុលា) ក៏ឱ្យ CDCam ធ្វើជាតំណាងឱ្យខ្លួន។ ក្រៅពី CDCam មាន NGO ជាច្រើនផ្សេងទៀត ក៏បានចូលរួមក្នុងការតស៊ូមតិដើម្បីផលប្រយោជន៍របស់ប្រជាជនដែលទទួលរងផលប៉ះពាល់ក្រោមគម្រោងនេះផងដែរចាប់ពីដើមឆ្នាំ២០០២រហូតមក។ អង្គការទាំងនោះ រួមមាន វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ជំនួយផ្នែកច្បាប់នៅកម្ពុជា អង្គការឃ្លាំមើលតំបន់មេគង្គ អង្គការ Oxfam របស់ប្រទេសអូស្ត្រាលី គម្រោងគណនេយ្យភាពអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មានធនាគារ។

១០. IRC ដែលស្ថិតនៅក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺជាស្ថាប័នរដ្ឋាភិបាលដ៏សំខាន់ ដែលមានទំនាក់ទំនងនឹងបណ្តឹងនេះ។ IRC ទទួលខុសត្រូវលើគ្រប់បញ្ហាពាក់ព័ន្ធនឹងការតាំងទីលំនៅឡើងវិញក្នុងប្រទេស និងមានតួនាទីច្បាស់លាស់សម្រាប់ការដោះស្រាយពាក្យបណ្តឹងទាមទារ ពាក់ព័ន្ធនឹងការតាំងទីលំនៅឡើងវិញ។ IRC បានចូលរួមយ៉ាងសកម្មក្នុងការអនុវត្តតាមអនុសាសន៍ដែលបានមកពីការធ្វើសវនកម្មលើការតាំងទីលំនៅឡើងវិញ និងបានខិតខំប្រឹងប្រែងពិចារណាលើបញ្ហានេះ។ IRC មិនគាំទ្រចំពោះបណ្តឹងនាពេលបច្ចុប្បន្ននេះឡើយ ដោយយល់ឃើញថា បណ្តឹងទាំងនេះផ្តល់ផលវិបាកដែលមានភាពច្រំដែលទៅនឹងការពិភាក្សាពីពេលមុន-បច្ចុប្បន្ន និងពុំមានប្រយោជន៍ដល់ដំណោះស្រាយចំពោះករណីដែលកំពុងកើតមានឡើយ។ បន្ថែមទៅលើតួនាទីរបស់ IRC ស្ថានប័នរដ្ឋាភិបាលនៅថ្នាក់ខេត្ត និងស្រុក ក៏មានតួនាទីជុំវិញបណ្តឹងនេះដែរ ពីព្រោះស្ថាប័នទាំងនោះជាអ្នកផ្តល់កម្មសិទ្ធិដីធ្លី ឬលិខិតកាន់កាប់ដីធ្លី។

១១. ADB និង CARM មានចំណែកច្បាស់លាស់ក្នុងគម្រោងនេះ។ ADB បានផ្តល់កម្ចីដល់គម្រោង និងជំនួយឥតសំណងដល់ TA ដែលគាំទ្រដល់ការធ្វើសវនកម្មលើការតាំងទីលំនៅឡើងវិញ និងបានផ្តោតការយកចិត្តទុកដាក់ជាខ្លាំងចំពោះគម្រោងនេះ និងបញ្ហានានាជុំវិញការតាំងទីលំនៅឡើងវិញ ជាពិសេសការអនុវត្តតាមអនុសាសន៍បានពីការធ្វើសវនកម្មលើការតាំងទីលំនៅឡើងវិញ។ CARM ដែលបានធ្វើការគ្រប់គ្រងលើគម្រោងនេះចាប់ពីឆ្នាំ២០០២ មក ជាភាគីពាក់ព័ន្ធសំខាន់ និងអាចដើរតួយ៉ាងសំខាន់ក្នុងការស្វែងរកដំណោះស្រាយលើបណ្តឹងទាមទារ។

## គ. លទ្ធផលរកឃើញ និងអនុសាសន៍

១២. RAR បានបញ្ចូលបញ្ហាគម្រោងនេះ ទៅក្នុងផ្នែកសំខាន់ ២ គឺ កម្មសិទ្ធិដីធ្លី និងការបង្កឱ្យមានភាពក្រីក្រ។

១៣. **កម្មសិទ្ធិដីធ្លី** : ដើមបណ្តឹងបានសម្តែងនូវកង្វល់ជាខ្លាំងចំពោះការដែលខ្លួនមិនទាន់ទទួលបានកម្មសិទ្ធិដីធ្លីដែលខ្លួនបានរើទៅនៅ បន្ទាប់ពីមានការសាងសង់ផ្លូវថ្នល់មក។ អ្នកទាំងនោះមានការព្រួយបារម្ភថា ប្រសិនបើគ្មានកម្មសិទ្ធិដីធ្លីទេ ពួកគាត់អាចងាយនឹងបាត់បង់ដីរបស់ខ្លួន។ IRC ត្រូវអនុវត្តស្របតាមច្បាប់របស់ប្រទេសកម្ពុជា ពោលគឺការផ្តល់ កម្មសិទ្ធិដីធ្លីអាចធ្វើឡើងបាន លុះត្រាតែប្រជាជនដែលទទួលរងផលប៉ះពាល់ បានរស់នៅលើដីរបស់ខ្លួននោះរយៈពេល យ៉ាងតិច ៥ឆ្នាំ។ ប៉ុន្តែជាក់ស្តែង ប្រជាជនដែលទទួលរងផលប៉ះពាល់មួយចំនួន បានមករស់នៅលើដីថ្មីរបស់ខ្លួនអស់ រយៈពេល ៥ឆ្នាំ ឬលើសពីនេះ តែនៅពុំទាន់ទទួលបានកម្មសិទ្ធិដីធ្លីនៅឡើយទេ។

១៤. **ការបង្កឱ្យមានភាពក្រីក្រ :** ដើមបណ្តឹងជាច្រើនបានបាត់បង់ប្រភពសម្រាប់ប្រកបរបរចិញ្ចឹមជីវិតរបស់ខ្លួន ចាប់ពីខ្លួន ត្រូវបានបង្ខំឱ្យផ្លាស់ប្តូរទីលំនៅ ហើយក៏ពុំទទួលបានកម្មវិធីណាមួយ ដែលចុះមកជួយស្តារជីវភាពរបស់អ្នកទាំងនោះ បន្ទាប់ពីផ្លាស់ប្តូរទីលំនៅដែរ។ បន្ទាប់ពីធ្វើការផ្លាស់ប្តូរទីលំនៅ និងក្នុងរយៈពេលផ្លាស់ប្តូរទីលំនៅបានពី ៥ ទៅ ៦ឆ្នាំ ក្នុងឆ្នាំ២០០០ នេះ និងការបង់ប្រាក់សំណងចុងក្រោយនៅឆ្នាំ២០០៥-២០០៦ (យោងតាមសវនកម្មលើការតាំងទីលំនៅថ្មី) ដើមបណ្តឹងមួយចំនួនមានការខ្វះខាតប្រាក់សម្រាប់រៀបចំដី និងផ្ទះថ្មី ព្រមទាំងសម្ភារប្រើប្រាស់ប្រចាំថ្ងៃ។ ការបាត់បង់ប្រភពចំណូលពីមុនមិនថាតិចតួច ឬច្រើនក្តី ពោលគឺតាមករណីផ្សេងៗ និងកង្វះលទ្ធភាពខ្ចីប្រាក់ពីធនាគារ ដោយសារពុំមានកម្មសិទ្ធិដីធ្លីនោះ ជាមូលហេតុបណ្តាលឱ្យដើមបណ្តឹងជាច្រើនបានបន្តខ្ចីប្រាក់ពីអ្នកផ្តល់ប្រាក់កម្ចីក្នុងអត្រាការប្រាក់ខ្ពស់។ អាស្រ័យហេតុនេះ អ្នកទាំងនោះបានធ្លាក់ខ្លួនជំពាក់បំណុលគេយ៉ាងធ្ងន់ធ្ងរ ចាប់ពីរាប់រយទៅជារាប់ពាន់ដុល្លារ ហើយមានការរំពឹងតិចតួចណាស់ថានឹងអាចដោះបំណុលនោះបាន។ ដើមបណ្តឹង ជឿជាក់ថាកម្មវិធីជីវភាព និងការកាត់បន្ថយបំណុលមួយចំនួន មានប្រយោជន៍ចំពោះខ្លួន ដើម្បីស្តារលក្ខខណ្ឌរស់នៅរបស់ខ្លួនឱ្យវិលមកកាន់ស្ថានភាព ដូចមុនពេលអនុវត្តគម្រោង។

## ឃ. ការចាត់វិធានការដែលបានស្នើឡើង

១៥. RAR បានដឹងថា ការតាំងចិត្តចំពោះដំណើរការផ្តល់ប្រឹក្សាពីសំណាក់ភាគីពាក់ព័ន្ធសំខាន់ៗ នៅមានលក្ខណៈស្រពេចស្រពិល។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ IRC និង CARM មានការជឿជាក់ថា ខ្លួនអាចដោះស្រាយបញ្ហា ដែលកើតមានបាន ដោយមិនអាស្រ័យនឹងដំណើរការប្រឹក្សារបស់ OSPF ឡើយ។ ម្យ៉ាងវិញទៀត ដើមបណ្តឹងក៏ពុំមានទំនុកចិត្តដែរថា វិធីសាស្ត្រនេះ នឹងទទួលបានជោគជ័យ ឬយ៉ាងណានោះទេ។ លើសពីនេះ នៅមានមធ្យោបាយដោះស្រាយមួយចំនួនអាចប្រើប្រាស់បាន ដោយអាចផ្តល់លទ្ធផលគាប់ប្រសើរ។ RAR បានសន្មតថា ខណៈពេលដែលពុំអាចព្យាករណ៍បានច្បាស់លាស់អំពីលទ្ធភាពនៃការដោះស្រាយបញ្ហារបស់ដើមបណ្តឹង ជាទូទៅ ត្រូវបន្តដំណើរការនេះទៀត។

១៦. ក្នុងកាលៈទេសៈបែបនេះ RAR បានផ្តល់អនុសាសន៍ថា មធ្យោបាយប្រសើរបំផុត គឺត្រូវបន្តបោះជំហានទៅមុខ ដូចមានក្នុងដំណើរការពិគ្រោះយោបល់របស់ OSPF[7] រួមមាន ២ចំណុចសំខាន់ៗ គឺ ១ សម្រាប់ដើមបណ្តឹង និងមួយទៀតសម្រាប់ OSPF។ OSPF គួរផ្តល់ RAR ជាភាសាអង់គ្លេស និងខ្មែរ ដល់ដើមបណ្តឹង និង CARM ដោយធ្វើការពន្យល់ដល់ដើមបណ្តឹងថា ពួកគេត្រូវសម្រេចចិត្តថា តើគួរបន្តដំណើរការផ្តល់ប្រឹក្សា ឬបញ្ឈប់ ប្រសិនបើពួកគេដឹងថា ដំណើរការនេះមិនមានគោលដៅជាក់លាក់ទេនោះ (និងរៀបចំឯកសារសម្រាប់ការពិនិត្យឡើងវិញ ប្រសិនបើអ្នកទាំងនោះចង់បាន)។ ដើម្បីជួយដើមបណ្តឹងឱ្យបានជ្រួតជ្រាបអំពី RAR និងការសម្រេចចិត្តដែលខ្លួនបានធ្វើកន្លងមកក្នុងដំណើរការផ្តល់ប្រឹក្សានោះ OSPF បានស្នើឱ្យផ្តល់អ្នកប្រឹក្សាឯករាជ្យមួយរូបដល់អ្នកទាំងនោះ។ ប្រសិនបើពួកគាត់បាន សម្រេចចិត្តថានឹងបន្តកិច្ចពិគ្រោះយោបល់ OSPF នឹងសាកសួរអ្នកទាំងនោះ ហើយឱ្យ CARM នឹងផ្តល់យោបល់អំពី លទ្ធផលរកឃើញរបស់ OSPF ដូចមានរៀបរាប់ក្នុងរបាយការណ៍នេះ។ អ្នកផ្តល់ប្រឹក្សាឯករាជ្យ នឹងជួយដើមបណ្តឹង ទាំង នោះ

---

[7] ជំហាននៃដំណើរការផ្តល់ប្រឹក្សារបស់ OSPF មានបង្ហាញក្នុងវិបសាថ៍របស់ OSPF (http://www.adb.org/spf/consultation-process.asp) និងមានរៀបរាប់ជាលម្អិតក្នុង *OSPF Consultation Primer* http://www.adb.org/Documents/SPF/OSPF-Primer.pdf

ក្នុងការរៀបចំមតិយោបល់។ ដោយផ្អែកលើចម្លើយទាំងនេះ OSPF នឹងធ្វើការវាយតម្លៃឡើងវិញ ថាតើដំណើរការផ្ដល់ការពិគ្រោះយោបល់នឹងប្រព្រឹត្តិទៅប្រកបដោយជោគជ័យ ឬយ៉ាងណា និងជំហានបន្ទាប់ ដោយផ្អែកលើការវាយតម្លៃនេះ។ បន្ទាប់មក OSPF នឹងផ្ដល់ជាអនុសាសន៍ដល់នាយក ADB ដើម្បី (i) បន្ត និងអនុវត្តវិធានការដោយប្រឹក្សាជាមួយដើមបណ្ដឹង CARM និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/IRC ឬ (ii) បូកសរុបដំណើរការផ្ដល់ប្រឹក្សាពីព្រោះការបន្តធ្វើការពិនិត្យឡើងវិញ នឹងពុំមានគោលដៅជាក់លាក់អ្វីឡើយ។

១៧. RAR បានផ្ដល់ជាអនុសាសន៍ថា ប្រសិនបើការសម្រេចចិត្តធ្វើឡើង ដើម្បីបន្តដំណើរការផ្ដល់ប្រឹក្សា OSPF ឬក្រុមសម្របសម្រួលផ្សេងទៀត ត្រូវរៀបចំផែនការដើម្បីជួបប្រជុំជាបន្តបន្ទាប់ (និងការចុះទស្សនកិច្ច ប្រសិនបើចាំបាច់) ដោយមានការចូលរួមពីសំណាក់ភាគីពាក់ព័ន្ធ ព្រមទាំងរៀបចំ និងសម្របសម្រួលកិច្ចប្រជុំទាំងនោះ។ RAR ក៏បានរៀបចំជំហាននានាដែលចាំបាច់សម្រាប់ការរៀបចំកិច្ចប្រជុំបន្តបន្ទាប់ និងលើកឡើងពីថ្លៃចំណាយផ្សេងៗដែលជាបន្ទុករបស់ OSPF។ OSPF បានផ្សព្វផ្សាយដល់ RAR នៅ ADB នាថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៤ និងដើមបណ្ដឹង (បន្ទាប់ពីបកប្រែជាភាសាខ្មែរ) នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៧។

## ៣. ទិសដៅសកម្មភាព

១៨. ការបន្តទិសដៅសកម្មភាពដែលបានស្នើក្នុងរបាយការណ៍បូកសរុប និងវាយតម្លៃ OSPF បានជ្រើសរើសអ្នកប្រឹក្សាក្នុងស្រុកឱ្យធ្វើជាទីប្រឹក្សាឯករាជ្យ ក្នុងខែវិច្ឆិកា ឆ្នាំ២០០៧ ហើយទីប្រឹក្សានេះបានទទួលការណែនាំរយៈពេលខ្លីនៅក្នុងទីក្រុងម៉ានីល។ ទីប្រឹក្សានោះ បានជួបនឹងដើមបណ្ដឹងក្នុងខែធ្នូ ឆ្នាំ២០០៧ ដើម្បីពន្យល់ពី RAR ដល់ពួកគេឱ្យបានលម្អិត និងដើម្បីប្រាកដថា អ្នកទាំងនោះយល់ពីសារៈសំខាន់នៃការសម្រេចចិត្តរបស់ខ្លួន ទាក់ទិននឹងសកម្មភាព ដែលពាក់ព័ន្ធនឹងដំណើរការពិគ្រោះយោបល់។ អំឡុងពេលប្រជុំជាមួយទីប្រឹក្សានោះ ដើមបណ្ដឹងចំនួន ៥២នាក់ ក្នុងចំណោម ៦៣នាក់ បានបញ្ជាក់ ថា ពួកគាត់ចង់បន្តដំណើរការពិគ្រោះយោបល់នេះ។

១៩. ស្របពេលគ្នានេះដែរ ក្នុងខែវិច្ឆិកា ឆ្នាំ២០០៧ CARM បានសម្ភាស ៦៣គ្រួសារ និងបានរៀបចំកិច្ចប្រជុំក្នុងខែវិច្ឆិកា និងធ្នូ ដើម្បីពិភាក្សាពីលទ្ធផលដែលទទួលបានពីបទសម្ភាសន៍ និងពិចារណាពីជំហានបន្ទាប់។ CARM, IRC និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនទៀត បានយល់ព្រមបន្តដំណើរការក្នុងការទាមទារឱ្យមានការពិចារណាលើចម្លើយរបស់ដើមបណ្ដឹងក្នុងអំឡុងពេលធ្វើបទសម្ភាស និងការផ្ដល់មតិយោបល់ពីអង្គការមិនមែនរដ្ឋាភិបាល រួមជាមួយនឹងទស្សនក្នុងការដោះស្រាយបញ្ហាដែលបានលើកឡើង។

២០. ការពិចារណាលើការសម្រេចចិត្តរបស់ដើមបណ្ដឹង ដើម្បីបន្តដំណើរការពិគ្រោះយោបល់នេះ OSPF ក្នុងខែមករា ឆ្នាំ២០០៨ បានស្នើឱ្យដើមបណ្ដឹង និង CARM ឱ្យផ្ដល់ជាមតិយោបល់ដល់ RAR។ CARM បានផ្ដល់មតិយោបល់ ប៉ុន្តែដើមបណ្ដឹងមិនបានផ្ដល់មតិយោបល់ទេ ហើយផ្ទុយទៅវិញបានស្នើ OSPF ឱ្យពន្យារពេល ដំណើរការពិគ្រោះយោបល់ ខណៈពេលដែលកិច្ចប្រឹងប្រែងរបស់ CARM និង IRC ដើម្បីដោះស្រាយបញ្ហារបស់ពួកគេទើបតែចាប់ផ្តើម[៨]។ ពួកគេមិនប្រាកដថាតើកិច្ចប្រឹងប្រែងទាំងនោះ នឹងទទួលបានជោគជ័យដែរឬទេ ហើយចាត់ទុក OSPF

[៨] ការស្នើសុំការផ្ដល់មតិយោបល់របស់ OSPF's និងសំណើសុំពន្យារពេលដំណើរការពិគ្រោះយោបលរបស់ដើមបណ្ដឹង ត្រូវបានដាក់បញ្ជូននៅថ្ងៃតែមួយ និងមានការខ្វែងគំនិតគ្នាក្នុងការឆ្ពោះទៅកាន់គោលដៅ។

ជាប្រភពជំនួយចុងក្រោយក្នុងករណីដែលដំណោះស្រាយមួយមិនអាចឈានទៅរកលទ្ធផលចង់បាន។ OSPF បានយល់ព្រមពន្យារដំណើរការរបស់ខ្លួន និងរង់ចាំលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរួមគ្នានៃ CARM និង IRC ដើម្បីដោះស្រាយបញ្ហា ដែលបាន លើកឡើងដោយដើមបណ្តឹង។ ក្នុងខែបន្តបន្ទាប់ ខណៈពេលដែលដំណើរការពិគ្រោះយោបល់ត្រូវបានធ្វើឡើង OSPF បានរក្សាទំនាក់ទំនងជាមួយដើមបណ្តឹងរួមជាមួយនឹងជំនួយពី CDCam ។

២១. កិច្ចខិតខំប្រឹងប្រែងរបស់ CARM និង IRC ក្នុងការដោះស្រាយបញ្ហារបស់ដើមបណ្តឹង ត្រូវបានពន្យារពេលដោយមូលហេតុផ្សេងៗ ប៉ុន្តែក្នុងខែតុលា ឆ្នាំ២០០៩ ធនាគារអភិវឌ្ឍអាស៊ី ADB បានយល់ព្រមផ្តល់ជំនួយបច្ចេកទេសដែលរួមមានកម្មវិធីកែប្រែប្រាក់ចំណូល ក្នុងគោលបំណងជួយដោះស្រាយបំណុលដែលកើនឡើងដល់ពួកគេ និងបង្កើតឡើងវិញនូវសកម្មភាពចិញ្ចឹមជីវិតរបស់ប្រជាជនទាំងនោះ[៩]។ ការវិវត្តនេះ អាចនឹងផ្តល់ក្តីសង្ឃឹមសម្រាប់ដោះស្រាយបញ្ហា ដែលបណ្តឹងទាមទារជាច្បាប់ដើម បានប្រគល់ឱ្យ OSPF។ ដោយយល់ឃើញថា ដំណើរការពិគ្រោះយោបល់ ត្រូវបានពន្យារពេលអស់រយៈពេលជិតពីរឆ្នាំ OSPF បានកំណត់ថា ការងារបន្ថែមរបស់ខ្លួនដែលពាក់ព័ន្ធនឹងដំណើរការនេះ អាចនឹងមិនសម្រេចបានតាមបំណង និងមិនត្រូវបានផ្តល់ព័ត៌មានពីបណ្តឹងទាមទារក្នុងខែវិច្ឆិកា ឆ្នាំ២០០៩ ដែលអាចមានការពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនឹងបណ្តឹងទាមទារនេះ។ ដើមបណ្តឹងមិនច្បាស់ក្នុងចិត្តថា ជំនួយបច្ចេកទេស អាចនឹងដោះស្រាយបញ្ហាបានឡើយ ហើយ OSPF ប្រាប់អ្នកទាំងនោះថា ពួកគេអាចត្រឡប់មកជួប OSPF វិញ ប្រសិនបើពួកគេគិតថា កម្មវិធីនេះ អាចនឹងមានផលប៉ះពាល់ដល់ពួកគាត់វិញ។

២២. ក្នុងខែឧសភា ឆ្នាំ២០១០ អ្នកសម្របសម្រួលគម្រោងពិសេស បានធ្វើទស្សនកិច្ចតាមសហគមន៍ជាមួយនឹងទីប្រឹក្សា ដែលបានជួលក្រោមជំនួយបច្ចេកទេស និងអ្នកតំណាងរបស់ CARM និង IRC ដើម្បីបិទពាក្យបណ្តឹង និងប្រគល់បញ្ហារបស់ដើមណ្តឹងទៅឱ្យក្រុមជំនួយបច្ចេកទេស។ សមាជិកសហគមន៍ បានថ្លែងអំណរគុណចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ CARM និង IRC ហើយពួកគេមានសុទិដ្ឋិនិយមថា កម្មវិធីស្តារប្រាក់ចំណូលរបស់គេ អាចនឹងដោះស្រាយបញ្ហាទាំងនេះបាន។

---

[៩] ធនាគារអភិវឌ្ឍន៍អាស៊ី ឆ្នាំ២០០៩។ *ព្រះរាជាណាចក្រកម្ពុជា : ការអភិវឌ្ឍសមត្ថភាពសម្រាប់កម្មវិធីស្តារប្រាក់ចំណូល*។ Manila (TA 7366-CAM). http://www.adb.org/Projects/project.asp?id=43174